**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៩ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ អនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

បង្កើត **គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩** (COVID-19) ដែលមានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១-**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៤- ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៥- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៦- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធានប្រចាំការ |
| ៧- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | សមាជិក |

| | |
|---|---|
| ៩-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១២-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១៣-រដ្ឋមន្ត្រីក្រសួងព័ត៌មាន | សមាជិក |
| ១៤-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១៥-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៦-រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៧-រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១៨-ឯកឧត្តម **ស្វាយ ស៊ីថា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | សមាជិក |
| ១៩-ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | សមាជិក |
| ២០-អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២១-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ២២-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ២៣-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៤-ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ២៥-លោកជំទាវ **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២៦-លោកជំទាវ **ឱ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២៧-អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | សមាជិក។ |

***គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩*** (COVID-19) អាចអញ្ជើញរដ្ឋមន្ត្រី រដ្ឋលេខាធិការ ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ ឬអាចផ្តល់ការណែនាំឱ្យអនុវត្តវិធានការបន្ទាន់នានា តាមការចាំបាច់។

**ប្រការ២.-**

***គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩*** (COVID-19) មានភារកិច្ច ដូចតទៅ÷

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រជាតិពាក់ព័ន្ធការប្រយុទ្ធនឹងជំងឺកូវីដ១៩
- ដឹកនាំអនុវត្តផែនការយុទ្ធសាស្ត្រ ក្នុងការបង្ការ ការពារ ទប់ស្កាត់ និងគ្រប់គ្រងជំងឺកូវីដ១៩
- គ្រប់គ្រងផលប៉ះពាល់ លើទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គម ទាំងកម្រិតជាតិ និងអន្តរជាតិ
- ដឹកនាំ និងសម្របសម្រួលការអនុវត្តវិធានការជាអន្តរវិស័យ អន្តរស្ថាប័ន ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៣.-**

***គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩*** (COVID-19) ប្រើប្រាស់ ***គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩*** ដែលត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ ២៦ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០២០ ដែលមានឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាលជាប្រធាន ធ្វើជាលេខាធិការប្រចាំការ។

សមាសភាពជាក់ស្តែងនៃ **គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩** មានក្រុមការងារប្រតិបត្តិការក្រោមនិវាទចំនួន២ គឺ **ក្រុមការងារប្រតិបត្តិការបច្ចេកទេសនិងផ្គត់ផ្គង់** ដឹកនាំដោយលោកជំទាវ **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល និង**ក្រុមការងារប្រតិបត្តិការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ** ដឹកនាំដោយលោកជំទាវ ** អ៊ិ វណ្ណឌីន** រដ្ឋលេខាធិការក្រសួងសុខាភិបាល។

សមាសភាពជាក់ស្តែងនៃក្រុមការងារទាំងពីរ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ៤.-**

**គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩** (COVID-19) មានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ ក្រោមនិវាទដូចខាងក្រោម÷

- **គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ រាជធានី-ខេត្ត** ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និង មានអភិបាលរងនៃគណៈអភិបាលរាជធានី-ខេត្ត មួយរូប ជាអនុប្រធានប្រចាំការ និងមានប្រធានមន្ទីរសុខាភិបាល ស្នងការនគរបាល មេបញ្ជាការកងរាជអាវុធហត្ថ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត ជាសមាជិក។ សមាសភាពជាក់ស្តែង នៃគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ រាជធានី-ខេត្ត ត្រូវកំណត់ដោយដីការរបស់រដ្ឋបាលរាជធានី-ខេត្ត។

**គណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ រាជធានី-ខេត្ត** មានភារកិច្ចដឹកនាំកិច្ចប្រតិបត្តិការ ក្នុងការបង្ការ ការពារ ទប់ស្កាត់ និងគ្រប់គ្រងជំងឺកូវីដ១៩ នៅក្នុងដែនសមត្ថកិច្ច នៃរដ្ឋបាលរាជធានី ខេត្តនីមួយៗ។

- **គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩** (COVID-19) មានគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ ប្រចាំច្រកទ្វារអន្តរជាតិ ធ្វើជាអង្គភាពប្រតិបត្តិ ដែលដឹកនាំដោយប្រធានស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ និងមានតំណាងក្រសួងសុខាភិបាល និងប្រធានអង្គភាពពាក់ព័ន្ធប្រចាំច្រកទ្វារអន្តរជាតិនីមួយៗ ជាសមាជិក។

**ប្រការ៥.-**

**ក្រុមការងារប្រតិបត្តិការបច្ចេកទេសនិងផ្គត់ផ្គង់** មានភារកិច្ច ដូចតទៅ÷

- គ្រប់គ្រងឧប្បត្តិហេតុ និងការរៀបចំផែនការប្រតិបត្តិ
- ធ្វើការវាយតម្លៃហានិភ័យទៅតាមការចាំបាច់ជាក់ស្តែង
- សម្របសម្រួលក្រុមគ្រប់គ្រងឧប្បត្តិហេតុ និងដាក់ឱ្យដំណើរការបានទាន់ពេលវេលា
- រៀបចំផែនការធនធានមនុស្ស ធនធានសម្ភារ និងធនធានថវិកា ដើម្បីឆ្លើយតបទាន់ពេលវេលា
- តាមដានសភាពនៃការឆ្លងជំងឺ និងវាយតម្លៃហានិភ័យ និងរៀបចំយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ទាន់ពេលវេលា
- គ្រប់គ្រងសេវាមន្ទីរពិសោធន៍ ដោយមានការពិគ្រោះយោបល់ពីគ្រប់ដៃគូអន្តរជាតិ
- គ្រប់គ្រងផ្នែកសេវាព្យាបាល និងថែទាំដោយបង្កើតផែនការឆ្លើយតបបន្ទាន់សម្រាប់មន្ទីរពេទ្យ
- គ្រប់គ្រងការបង្ការ និងត្រួតពិនិត្យការចម្លងរោគ ដោយអនុវត្តវិធានការណ៍ប្រកបដោយសុវត្ថិភាព
- ធ្វើបច្ចុប្បន្នភាពឆ្លើយតបបន្ទាន់សម្រាប់ច្រកចេញ-ចូលអាកាសយានដ្ឋាន កំពង់ផែ និងច្រកផ្លូវគោក
- ធានាការផ្គត់ផ្គង់ធនធានមនុស្ស ធនធានបរិក្ខារ និងឱសថ និងធនធានថវិកា និងរាល់ប្រតិបត្តិការ។

**ក្រុមការងារប្រតិបត្តិការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ** មានភារកិច្ច ដូចតទៅ÷

- រៀបចំវគ្គបណ្តុះបណ្តាល និងធ្វើលំហាត់សមយុទ្ធ ដើម្បីផ្សព្វផ្សាយការយល់ដឹងដល់មន្ត្រីសុខាភិបាល និងផ្នែកពាក់ព័ន្ធ
- ផ្សព្វផ្សាយទូលំទូលាយ នូវការទប់ស្កាត់ ការបង្ការ និងវិធាននានាចាំបាច់សម្រាប់ឆ្លើយតបនៃជម្ងឺ Covid-19
- គ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយសង្គមនានា រួមទាំងចាត់វិធានការចាំបាច់ ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បង្កើនសមត្ថភាពក្រុមឆ្លើយតបបន្ទាន់ និងរៀបចំប្រព័ន្ធទាន់ហេតុការណ៍ ដោយប្រើប្រាស់យន្តការពេញលេញ ដែលអាចវាយបកទៅគ្រប់ព័ត៌មានក្លែងក្លាយ និងព័ត៌មានប្រឌិត
- ផ្តល់ព័ត៌មានភ្លាមៗ ស្តីពីបច្ចុប្បន្នភាពនៃជម្ងឺ និងការរាតត្បាតនៃជម្ងឺក្នុងចំណោមអ្នកដំណើរទាំងជាតិ និងអន្តរជាតិ និងសហគមន៍
- រក្សាទំនាក់ទំនងឱ្យបានទូលំទូលាយ ស្តីពីការទប់ស្កាត់ហានិភ័យ ដោយផ្តល់ព័ត៌មាន និងសារសំខាន់ៗទៅសាធារណៈជន និងផ្នែកពាក់ព័ន្ធដទៃទៀត
- តាមដានប្រព័ន្ធផ្សព្វផ្សាយជាតិ អន្តរជាតិ ព័ត៌មានទាន់ហេតុការណ៍ ព័ត៌មានត្រឡប់ពីអ្នកជំងឺ ដើម្បីកាត់បន្ថយនូវការព្រួយបារម្ភ និងការភិតភ័យពីប្រជាពលរដ្ឋ។

**ប្រការ៦.–**

យន្តការស្ថាប័ននិងមុខងារ ដែលត្រូវបានកំណត់ក្នុងសេចក្តីសម្រេចនេះ ត្រូវមានអានុភាពអនុវត្តរហូតដល់ការប្រយុទ្ធនឹងជំងឺកូវីដ១៩ ត្រូវបានបញ្ចប់ជាស្ថាពរ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដែលមានចែងក្នុងសេចក្តីសម្រេចនេះ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧ ង ១០ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ